# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍ដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ សូរិយា ស៊ូបេឌី

### រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១

បេសកកម្មស្វែងរកការពិតលើកទីប្រាំមួយរបស់ខ្ញុំ មកកាន់ព្រះរាជាណាចក្រកម្ពុជាជិតដល់ទីបញ្ចប់ហើយ។ ដំណើរបេសកកម្មនេះផ្តោតលើការវាយតំលៃអំពីសិទ្ធិមនុស្សនៃស្ថាប័នរដ្ឋនានា ទាក់ទងនឹងដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា រាប់ទាំងច្បាប់ គោលនយោបាយនានាដែលអាចអនុវត្តន៍ចំពោះការបោះឆ្នោត។ នៅអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ ខ្ញុំក៏មានបំណងធ្វើការវាយតំលៃអំពីភាពជឿនលឿនក្នុងការអនុវត្តន៍អនុសាសន៍ទាំងឡាយក្នុងរបាយការណ៍កន្លងមករបស់ខ្ញុំ ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ហើយខ្ញុំក៏បានឆ្លៀតឱកាសនេះបន្តឃ្លាំមើល និងលើកយកបញ្ហាសិទ្ធិមនុស្សមួយចំនួន ដែលកំពុងបន្តកើតមានក្នុងប្រទេសនេះមកពិភាក្សា ដូចជាទំនាស់ដីធ្លី សេរីភាពខាងការបញ្ចេញមតិ និងសេចក្តីស្នើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

នៅកំឡុងពេលបេសកកម្មនេះ ខ្ញុំអាចជួបជាមួយតួអង្គជាច្រើន រាប់ទាំងសង្គមស៊ីវិល គណៈបក្សនយោ បាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត ក្រសួងមហាផ្ទៃ នគរបាលជាតិកម្ពុជា ក្រសួងការពារជាតិ អ្នកអត្ថាធិប្បាយ អ្នកការទូតអន្តរជាតិ និងម្ចាស់ ជំនួយនានា និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។

ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ត្រូវបានពង្រឹងតាមរយៈការគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ មាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (កម្ពុជាគឺ ជារដ្ឋភាគីមួយ) ចែងថា ជនគ្រប់រូបមានសិទ្ធិរួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈនៅក្នុងប្រទេស និងបោះឆ្នោត (និងឈរឈ្មោះបោះឆ្នោត) " តាមរយៈការបោះឆ្នោតតាមកាលកំណត់ទៀងទាត់ពិតប្រាកដជាសកលស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត។

កម្ពុជាឈានមកដល់ពេលមួយដែលមានការបោះឆ្នោតពីរឆ្នាំជាប់ៗគ្នា គឺការបោះឆ្នោតឃុំ/សង្កាត់ ក្នុងឆ្នាំ២០១២ និងការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៣។ នេះគឺជាការបោះឆ្នោតជាតិលើកទីបួន ហើយដែលព្រះរាជាណាចក្រកម្ពុជារៀបចំធ្វើ ចាប់តាំងពីការបោះឆ្នោតដំបូងបង្អស់ក្នុងឆ្នាំ១៩៩៣ ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងរឹងមាំថា ប្រទេសកម្ពុជាជាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ហើយការបោះឆ្នោតគឺជាស្នូលនៃលទ្ធិប្រជាធិបតេយ្យ។

ប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស បានប្រកាន់យកលិទ្ធិប្រជាធិបតេយ្យ ដោយក្តីរំពឹងទុកដ៏ខ្ពស់ ហើយដំណើរទស្សនកិច្ចរបស់ខ្ញុំនៅទីនេះបង្ហាញជាថ្មីថាតើតួអង្គទាំងអស់ចូលរួមក្នុងការរៀបចំការបោះឆ្នោតនៅពេលខាងមុខមានការខិតខំប្រឹងប្រែងយ៉ាងមុតមាំយ៉ាងដូចម្តេច។ ប្រជាពលរដ្ឋកម្ពុជាសំឡឹងឃើញអនាគតរបស់ខ្លួនថាជាអនាគតមួយបែបប្រជាធិបតេយ្យ។ បន្ទាប់ពីមានប្រវត្តិសាស្ត្របែបប្រជាធិបតេយ្យខ្លីមួយនៅក្នុងប្រទេស ប្រជាពលរដ្ឋកម្ពុជាបានទម្លាប់ខ្លួនទៅនឹងគំនិតបោះឆ្នោត ហើយ អ្នកដែលទទួលខុសត្រូវចំពោះការរៀបចំការបោះឆ្នោតបានបង្កើនសមត្ថភាពរបស់ខ្លួនច្រើនក្រៃលែង ដើម្បីអនុវត្តកិច្ចការនេះ។

បញ្ហាប្រឈមជាគន្លឹះគឺធ្វើយ៉ាងណាដើម្បីបណ្តុះសេចក្តីស្រេកឃ្លានលទ្ធិប្រជាធិបតេយ្យនៅក្នុងផ្នត់គំនិតរបស់យុវជនកម្ពុជា។ ខ្ញុំមានការពេញចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការបង្កើតកម្មវិធី ដើម្បីផ្សព្វផ្សាយការយល់ដឹងដល់ស្រទាប់យុវវ័យនៃព្រះរាជាណាចក្រកម្ពុជាដែលកាន់តែមានចំនួនច្រើនឡើង។ លើសពីនេះទៀត ចាប់តាំងពីការបោះ

ឆ្នោតលើកដំបូងក្នុងឆ្នាំ១៩៩៣ រដ្ឋាភិបាលកម្ពុជា និងអ្នកដែលធ្វើការក្នុងស្ថាប័នបោះឆ្នោតបានបង្កើន ចំណេះដឹងរបស់ខ្លួនយ៉ាងច្រើននិងពង្រឹងលទ្ធភាពរបស់ខ្លួន ដើម្បីដំណើរការនិងរៀបចំការបោះឆ្នោត។

ខ្ញុំមានក្តីរីករាយ និងរាយការណ៍ថា មន្ត្រីរាជការដែលកំពុងបំរើការក្នុងក្រសួងនានារបស់រដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងស្ថាប័នរដ្ឋឯទៀត ក៏ដូចជាសង្គមស៊ីវិលទាំងអស់គ្នា សុទ្ធតែបានបង្ហាញប្រាប់ខ្ញុំនៅក្នុងពេលជំនួបប្រជុំថា ពួកគេមានការយល់ដឹងច្បាស់លាស់ណាស់ អំពីច្បាប់ និងការអនុវត្តន៍ដែលគ្រប់គ្រងលើដំណើរការបោះឆ្នោតនៅកម្ពុជា។

នៅក្នុងអំឡុងពេលបំពេញបេសកកម្មនេះ ខ្ញុំបានទទួលព័ត៌មានយ៉ាងច្រើនពីប្រជាជន និងស្ថាប័នផ្សេងៗដែលជារឿយៗពួកគាត់មានទស្សនៈផ្សេងៗគ្នា។ មានមនុស្សជាច្រើនបានបង្ហាញប្រាប់ខ្ញុំអំពីព័ត៌មានស្តីពីភាពប្រសើរឡើង ដែលសំរេចបាននៅក្នុងទសវត្សរ៍កន្លងមក ដើម្បីធ្វើឲ្យប្រាកដថាការបោះឆ្នោតប្រព្រឹត្តទៅស្របតាមទំលាប់អនុវត្តន៍ល្អៗជាអន្តរជាតិ។ មានអ្នកខ្លះទៀតបានបង្ហាញប្រាប់ខ្ញុំ ដោយពោលអះអាងអំពីភាពមិនប្រក្រតី ឬបញ្ហាដែលកើតមានជាប្រព័ន្ធដែលធ្វើឲ្យអន្តរាយដល់លទ្ធភាពរបស់ប្រទេសកម្ពុជាក្នុងការរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ខ្ញុំបានស្តាប់ និងកត់ត្រារាល់ព័ត៌មានទាំងនេះ។ ខ្ញុំនឹងត្រូវការធ្វើការពិនិត្យពិចារណាព័ត៌មានទាំងនេះយ៉ាងប្រយ័ត្នប្រយែង ហើយប្រសិនជាចាំបាច់ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានទាំងនេះ នៅមុនពេលខ្ញុំសរសេររបាយការណ៍។ ថ្ងៃនេះខ្ញុំអាចត្រឹមតែលើកយកបញ្ហាមួយចំនួន ដែលគេប្រាប់ឲ្យខ្ញុំដឹងតែប៉ុណ្ណោះ។

ដើម្បីមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ប្រទេសមួយត្រូវការឲ្យមានសង្គមមួយបើកចំហ និងដែលចម្រើនលូតលាស់ ដើម្បីចែករំលែកមតិ គំនិត និងយោបល់។ មតិរិះគន់ចំពោះរដ្ឋាភិបាលគឺជាការកើតមានជាធម្មតា នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យនៅបស្ចឹមប្រទេសរហូតដល់ប្រទេសនៅប្លុកខាងកើត យើងអាចមើលឃើញថាប្រទេសទាំងឡាយណាដែលមានសង្គមមួយបើកចំហរ ជួយជំរុញលើកទឹកចិត្តឲ្យរដ្ឋាភិបាលគិតគូឡើងវិញ ការជជែកដេញដោល និងទទួលយកមកពិនិត្យពិចារណានូវមតិយោបល់ថ្មីៗ ដែលមានគោលដៅផ្តល់ជាគុណប្រយោជន៍ដល់ប្រទេសជាតិទាំងមូល។ ដូច្នេះ សេចក្តីត្រូវការឲ្យមានគណបក្សប្រឆាំងមួយដែលអាចប្រព្រឹត្តទៅបាន និងមាន

ប្រសិទ្ធភាព គឺជាការសំខាន់បំផុត ព្រោះថាវាដើរតួនាទីជាអ្នកពិនិត្យ និងថ្លឹងថ្លែងលើនយោបាយ សកម្មភាព និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ ម្យ៉ាងវិញទៀត គណបក្សប្រឆាំងអាចធ្វើការជាមួយរដ្ឋាភិបាលក្នុងការគៀងគរប្រជាពលរដ្ឋឲ្យចូលរួមកាន់តែច្រើន ជាពិសេសក្នុងករណីនៃការបោះឆ្នោតតែម្តង ព្រោះថាវាផ្តល់អត្ថប្រយោជន៍ឲ្យទាំងខាងរដ្ឋាភិបាល និងខាងគណបក្សប្រឆាំងប្រសិនជាមានប្រជាពលរដ្ឋមកបោះឆ្នោតកាន់តែច្រើនឡើង។

បរិបទទូទៅនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស ដែលកំពុងប្រព្រឹត្តទៅពង្រឹងការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ឥឡូវនេះ ខ្ញុំសូមងាកមកការរៀបចំការបោះឆ្នោតវិញម្តង។

ខ្ញុំមានកង្វល់អំពីព័ត៌មានដែលខ្ញុំបានទទួលទាក់ទងនឹងការថយចុះនៃចំនួនអ្នកបោះឆ្នោត និន្នាការថយចុះនៃការចូលរួមបោះឆ្នោត និងការធុញទ្រាន់នៃអ្នកបោះឆ្នោត។ មានហេតុផលជាច្រើន ដែលបុគ្គលម្នាក់ៗអាចសំរេចចិត្តមិនចូលរួមក្នុងដំណើរការបោះឆ្នោត។ ទោះជាដូច្នោះក្តី ក្នុងករណីជាច្រើនប្រជាពលរដ្ឋមិនជ្រើសរើសយកការបោះបង់សិទ្ធិបោះឆ្នោតរបស់ខ្លួនទេ ប៉ុន្តែពួកគេប្រឈមមុខនឹងឧបសគ្គសំខាន់ៗមួយចំនួន ដែលនាំឲ្យពួកគេបោះបង់ចោលទាំងស្រុងនូវសិទ្ធិបោះឆ្នោតរបស់ខ្លួន។

បន្ទាប់ពីដំណើរទស្សនកិច្ចនេះ ខ្ញុំនឹងពិនិត្យយ៉ាងដិតដល់អំពីលទ្ធភាពរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះបំផុតក្នុងសង្គម មានជាអាទិ៍ ជនក្រីក្រ ជនគ្មានទីជម្រក ជនត្រូវគេបណ្តេញចេញពីដីធ្លីដើម្បីមើលថាតើពួកគាត់អាចប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការបោះឆ្នោតបានពិតប្រាកដឬយ៉ាងណា។ ខ្ញុំសង្ឃឹមថានឹងអាចផ្តល់ជាអនុសាសន៍មួយចំនួនជូនរាជរដ្ឋាភិបាល ដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។

កង្វល់មួយចំនួនទៀត ត្រូវបានលើកយកមកពិភាក្សាជាមួយខ្ញុំ ហើយខ្ញុំមានបំណងធ្វើការសិក្សាអំពីកង្វល់នីមួយៗទាំងនោះយ៉ាងប្រយ័ត្នប្រយែងបំផុត។

- កង្វល់ទីមួយគឺតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងការបោះឆ្នោត និងកង្វល់ផ្សេងៗទៀត ដែលថាគណបក្សនយោបាយមួយចំនួនត្រូវបានគេបដិសេធលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្មើភាពជាមួយគណបក្សដទៃផ្សេងទៀត។

- កង្វល់មួយទៀតគឺការប្រើប្រាស់ធនធានរដ្ឋដោយគណបក្សនយោបាយផ្សេងៗ នៅក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត រាប់ទាំងពេលវេលារបស់បុគ្គលិក មន្ត្រីរាជការ រថយន្ត គ្រឿងសម្ភារៈ។ ខ្ញុំមានក្តីរីករាយដែលបានទទួលការធានាអះអាងពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃថា រដ្ឋាភិបាលនឹងចេញសេចក្តីណែនាំដល់មន្ត្រីរាជការ នគរបាល និងបុគ្គលិកយោធានទាំងអស់ថា ពួកពួកគេមិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយណាមួយ នៅក្នុងពេលបំពេញតួនាទីក្នុងសមត្ថភាពផ្លូវការរបស់ខ្លួន ដែលរាប់ទាំងការប្រើប្រាស់ធនធានរបស់រដ្ឋ ហើយថាការប្រកាន់ខ្ជាប់នូវអព្យាក្រឹត្យ0គឺជាប្រការដ៏សំខាន់បំផុត។

- ដៃគូពិភាក្សាខ្លះបានគូសបញ្ជាក់អំពីដំណើរការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខណៈស្មុគស្មាញ ហើយវិសាលភាពនៃដំណើរការនេះទៀតសោត បើកឲ្យមានភាពមិនប្រក្រតី។

- គណបក្សនយោបាយមួយចំនួនបានរាយការណ៍អំពីការគំរាមកំហែង ការបំភិតបំភ័យ និងការយាយីរំខាន (រាប់ទាំងចំណាត់ការតាមផ្លូវច្បាប់) ប្រឆាំងសមាជិក និងបេក្ខជនរបស់ខ្លួន។ ការអះអាងទាំងនេះជាការព្រួយបារម្ភយ៉ាងខ្លាំង ហើយខ្ញុំបានលើកយកបញ្ហានេះទៅពិភាក្សាជាមួយអាជ្ញាមួយចំនួន។ ខ្ញុំនឹងបន្តស្វែងរកព័ត៌មានថែមទៀតក្នុងបញ្ហាទាំងនេះ។

- ខ្ញុំដឹងអំពីស្ថានភាពរបស់ប្រធានគណបក្សនយោបាយសមរង្ស៊ី។ ខ្ញុំយល់ឃើញថាកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយដោយគណបក្សកាន់អំណាច និងគណបក្សប្រឆាំងឈានទៅកាន់ការផ្សះផ្សាគ្នាមួយ គឺជាអត្ថប្រយោជន៍នៃលទ្ធិប្រជាធិបតេយនីយកម្មមួយ ដែលកាន់តែខ្លាំង និងស៊ីជម្រៅជាងនេះថែមទៀតនៅក្នុងប្រទេស។

មុននឹងបញ្ចប់ ខ្ញុំសូមលើកគ្រួសៗអំពីបញ្ហាទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ខ្ញុំមានក្តីពេញចិត្តចំពោះការសំរេចរបស់រាជរដ្ឋាភិបាល ដើម្បីតាក់តែងនូវសេចក្តីព្រាងច្បាប់ថ្មីមួយ និងជាសញ្ញាបង្ហាញពីបំណងប្រាថ្នារបស់រដ្ឋាភិបាលក្នុងការបន្តពិគ្រោះយោបល់ថែមទៀត ជាមួយសង្គមស៊ីវិលលើសេចក្តីព្រាងច្បាប់នេះ។ ខ្ញុំសូមស្នើយ៉ាងទទូចដល់រដ្ឋាភិបាលឲ្យផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថ្មីឲ្យបានយ៉ាងឆាប់តាមដែលអាចធ្វើបាន និងទុកពេល

វេលាគ្រប់គ្រាន់ និងភាពជាតំណាងឲ្យបានទូលំទូលាយពីសង្គមស៊ីវិល តាមដែលអាចធ្វើបានដើម្បីឲ្យការពិគ្រោះនេះសំរេចបានប្រកបដោយអត្ថន័យ។

សរុបសេចក្តីទៅ ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលសំរាប់កំរិតកិច្ចសហប្រតិបត្តិការល្អ ចំពោះរូបខ្ញុំ នៅក្នុងជំឡុងពេលបំពេញទស្សនកិច្ចនេះ។ ដៃគូពិភាក្សាដទៃទៀតរបស់ខ្ញុំបានបង្ហាញភាពសហការ និងរុះរាយរាក់ទាក់ រាប់ទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្គមស៊ីវិល ក្រុមអង្គការសហប្រជាតិប្រចាំប្រទេសកម្ពុជា និងម្ចាស់ជំនួយនានា។ ដូចសព្វដង ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សបានផ្តល់ការគាំទ្រដល់ខ្ញុំខាងភស្តុភា និងបច្ចេកទេស ចាំបាច់ដើម្បីបំពេញការងាររបស់ខ្ញុំ និងសូមអរគុណដល់ពួកគាត់។

ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ជាអ្នករាយការណ៍ពិសេសរបស់ អ.ស.ប ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០០៩។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិ នៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*រាល់សំណើព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចទំនាក់ទំនងមកការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ សូមទំនាក់ទំនងមក កញ្ញា ហ្ស៊ីអ៊ី ឡាធំបូ (តាមរយៈទូរស័ព្ទលេខ +៨៥៥ ០១២ ៧៩០ ១៧៨/ អ៊ីម៉េល zlatumbo@ohchr.org) ឬ លោក ទូច ហ្វន (ទូរស័ព្ទលេខ +៨៥៥ ០១២ ៨៧៦ ៥៩/ អ៊ីម៉េល htouch@ohchr.org)*